**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សាររំលែកមរណទុក្ខ

**គោរពជូន**
**ឯកឧត្តម ម៉ុក ម៉ារ៉េត សមាជិករដ្ឋសភា**
**និងជាអ្នកតំណាងរាស្ត្រមណ្ឌលខេត្តតាកែវ ព្រមទាំងក្រុមគ្រួសារ**

**ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ ជាទីរាប់អាន**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីសោកស្តាយជាពន់ពេក ដោយបានទទួលដំណឹងថា **លោកជំទាវមហាឧបាសិកា ឈា ឡាង** ជាភរិយារបស់ **ឯកឧត្តម** បានទទួលមរណភាព នៅថ្ងៃសៅរ៍ ៧កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង១១:៤៤នាទី នៅទីក្រុងប៉ារីស ប្រទេសបារាំង ត្រូវនឹងម៉ោង១៦:៤៤នាទី នៅរាជធានីភ្នំពេញ ក្នុងជន្មាយុ ៧០ឆ្នាំ ដោយរោគាពាធ។

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្តែងនូវសេចក្តីសោកស្តាយ ស្រណោះ អាឡោះអាល័យបំផុត ជាមួយ **ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ** ចំពោះការបាត់បង់ **លោកជំទាវមហាឧបាសិកា ឈា ឡាង** ជាភរិយា ជាម្តាយ ជាម្តាយក្មេក ជាជីដូនដែលប្រកបដោយសង្គហធម៌ដ៏ល្អប្រពៃ ព្រហ្មវិហារធម៌មិនចេះរីងស្ងួត និងជាអ្នកហ៊ានពលិកម្មសព្វបែបយ៉ាង ដើម្បីរួមដំណើរគាំពារ ជ្រោមជ្រែងដល់ **ឯកឧត្តម** ក្នុងការចូលរួមបម្រើជាតិមាតុភូមិ និងរួមចំណែកក្នុងការកសាង និងអភិវឌ្ឍជាតិឱ្យមានការរីកចម្រើនជារៀងរហូតមក ហើយក៏ជាការបាត់បង់នូវមហាកម្លាំងសាមគ្គីនៅក្នុងចលនាពុទ្ធសាសនូបត្ថម្ភក៏ផងដែរ។

យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងតេជៈបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ តាមជួយបីបាច់ថែរក្សាដល់ដួងវិញ្ញាណក្ខន្ធ **លោកជំទាវមហាឧបាសិកា ឈា ឡាង** សូមអញ្ជើញទៅកាន់សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ** មេត្តាទទួលនូវមនោសញ្ចេតនាចែករំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ៕

ថ្ងៃ ចន្ទ ៩ កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រំ សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh